SeeBeyondBorders

គោលនយោបាយ

# កិច្ចការពារសុវត្ថិភាព

*Change begins with Education*

SP/02/2021/2.0

# មាតិកា


1. សេចក្តីផ្តើម និងបុព្វកថា ........ 1
2. គោលបំណងនៃគោលនយោបាយ ........ 1
3. សេចក្តីថ្លែងការណ៍អំពីការបេជ្ញាចិត្ត ........ 2
4. តើអ្វីជាកិច្ចការពារសុវត្ថិភាព? ........ 3
5. វិសាលភាពនៃការអនុវត្តគោលនយោបាយ ........ 3
6. គោលការណែនាំសំខាន់ៗ ........ 3
7. និយមន័យ ........ 6
8. ការបង្ការទប់ស្កា ត់ ........ 9
   - ទំនួលខុសត្រូវរបស់អង្គការទស្សនៈឥតព្រំដែននិងស្តង់ដារប្រតិបត្តិ ........ 9
   - ការទទួលខុសត្រូវរបស់បុគ្គលិកនិងស្តង់ដានៃការប្រតិបត្តិ ........ 10
9. ការធ្វើរបាយការណ៍ ........ 11
   - របៀបរាយការណ៍អំពីបញ្ហាទាក់ទងនឹងកិច្ចការពារសុវត្ថិភាព ........ 12
10. ការឆ្លើយតប ........ 13
11. ការរក្សាការសំងាត់ ........ 13
12. គោលនយោបាយនិងនីតិវិធីដែលពាក់ព័ន្ធ ........ 14
13. ការគ្រប់គ្រងគោលនយោបាយ ........ 15

ឧបសម្ព័ន្ធ ក៖ ជនបង្គោលការពារសុវត្ថិភាព (Safeguarding Focal Points) ........ 16

## 1. សេចក្តីផ្តើម និងបុព្វកថា

អង្គការទស្សនៈឥតព្រំដែន(SeeBeyondBorders)គឺជាអង្គការមិនរកប្រាក់ចំណេញ ដែលបានចុះបញ្ជីជាអង្គការសប្បុរសធម៌នៅប្រទេសអូស្ត្រាលី អង់គ្លេស និងប្រទេសអៀរឡង់ ហើយប្រតិបត្តិក្នុងនាមជាអង្គការមិនមែនរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា។ បេសកកម្មរបស់យើងគឺផ្តល់អោយកុមារកម្ពុជាទទួលបាននូវគុណភាពនៃការបង្រៀននិងការសិក្សានៅតាមសាលារៀន។

បុគ្គលិក អ្នកស្ម័គ្រចិត្ត និងអ្នកចូលរួមកម្មវិធីរបស់អង្គការទស្សនៈឥតព្រំដែនធ្វើការនៅតាមសាលារៀនជាមួយលោកគ្រូអ្នកគ្រូ កុមារ និងមនុស្សវ័យក្មេង។ យើងទទួលស្គាល់តាមរយៈនៃការងារប្រតិបត្តិការរបស់យើងប្រហែលនឹងអាចបង្កហានិភ័យដល់កុមារយុវជននិង ជនងាយរងគ្រោះដែលជាអ្នកទទួលផល ដូចនេះយើងបានបង្កើតគោលនយោបាយការការពារនិងនីតិវិធីប្រកបដោយប្រសិទ្ធភាពដើម្បីធ្វើការយ៉ាងសកម្មក្នុងការកាត់បន្ថយហានិភ័យទាំងនោះ។ គោលការណ៍និងនីតិវិធីពាក់ព័ន្ធនេះគ្របដណ្តប់លើអង្គភាព SeeBeyondBorders ទាំងអស់។

## 2. គោលបំណងនៃគោលនយោបាយ

គោលនយោបាយនេះមានគោលបំណងការពារមនុស្សជាតិ ជាពិសេសកុមារ មនុស្សពេញវ័យជួបហានិភ័យនិងអ្នកទទួលផលពឹងផ្អែកជំនួយពីអ្នកដទៃ ឱ្យចាកផុតពីគ្រោះភ័យណាមួយដែលអាចបណ្តាលមកពីការទាក់ទងឬចូលរួមកម្មវិធីជាមួយ អង្គការទស្សនៈឥតព្រំដែន។ ក្នុងនោះរួមមានគ្រោះថ្នាក់ដែលកើតឡើងពី៖

- ការប្រតិបត្តិរបស់មនុស្សជាបុគ្គលិកឬតំណាងអង្គការទស្សនៈឥតព្រំដែនដូចបានកំណត់ក្នុងផ្នែកទី4
- ការតាក់តែងនិងការអនុវត្តកម្មវិធីនិងសកម្មភាពរបស់អង្គការទស្សនៈឥតព្រំដែន

គោលនយោបាយនេះបង្ហាញពីការប្តេជ្ញាចិត្តរបស់អង្គការទស្សនៈឥតព្រំដែន និងបុគ្គលិកដែលមានទំនួលខុសត្រូវក្នុងកិច្ចការកាពារសុវត្ថិភាព ដែលរួមបញ្ចូលទាំងកិច្ចបង្ការហានិភ័យពីការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភផ្លូវភេទ និងការបៀតបៀនកេរ្តិ៍ខ្មាស់ (PSEAH)។ គោលនយោបាយកិច្ចការពារសុវត្ថិភាពត្រូវប្រតិបត្តិការរួមជាមួយគោលនយោបាយប្រឆាំងការរើសអើង ការគំរាមកំហែងនិងការបៀតបៀនកេរ្តិ៍ខ្មាស់របស់ SeeBeyondBorders និងគោលនយោបាយការពារកុមារនិងជនងាយរងគ្រោះរបស់ SeeBeyondBorders។

## 3. សេចក្តីថ្លែងការណ៍អំពីការប្តេជ្ញាចិត្ត

SeeBeyondBorders ប្តេជ្ញាការពារអ្នករាល់គ្នាដែលយើងទាក់ទង ដោយមិនប្រកាន់ពី អាយុ អត្តសញ្ញាណយេនឌ័រ ពិការភាព និន្នាការភេទ ឬដើមកំណើតជនជាតិដើមអ្វីឡើយ ព្រោះយើងជឿជាក់ថា មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការការពារពីគ្រប់ទម្រង់នៃគ្រោះភ័យ ការកេងប្រវ័ញ្ច ការរំលោភបំពាន និងការបៀតបៀន។ SeeBeyondBorders នឹងមិនអត់អោនចំពោះការរំលោភបំពាន និងការកេងប្រវ័ញ្ចប្រព្រឹត្តដោយបុគ្គលិក អ្នកស្ម័គ្រចិត្ត ឬអ្នកមកទស្សនាណាម្នាក់ ឡើយ។

គោលនយោបាយនេះផ្តោតលើការការពារដូចតទៅ៖ ការការពារកុមារ ការការពារមនុស្សពេញវ័យ និងការការពារការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពាន និងការបៀតបៀន។ សមាសភាគការពារសំខាន់ៗទាំងនេះ អាចមានគោលនយោបាយនិងនីតិវិធីពាក់ព័ន្ធផ្សេងៗគ្នា (សូមមើលគោលនយោបាយពាក់ព័ន្ធ) ។

យើងទទួលស្គាល់ថា វាជាធម្មជាតិដែលគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ខ្លះអាចបង្កឱ្យមានអតុល្យភាពអំណាចក្នុងទំនាក់ទំនងសហគមន៍កាន់តែអាក្រក់។ ដូច្នេះវាទាមទារឱ្យមានការយកចិត្តទុកដាក់ជាប់ជានិច្ចក្នុងការធានាស្តង់ដារវិជ្ជាជីវៈ និងក្រមសីលធម៌កម្រិតខ្ពស់។ យើងប្តេជ្ញាចិត្តប្រកាន់យកឥរិយាបថមិនរើសអើង និងប្រកបដោយការគោរព ដោយមិនអនុគ្រោះចំពោះទង្វើមិនប្រាសក្រមសីលធម៌ ដោយគ្មានការរំលោភអំណាច ហើយគ្មានការកេងចំណេញពីភាពងាយរងគ្រោះ និងវិសមភាពអំណាចឡើយ។

យើងនឹងធានាថាវិធានការការពារសុវត្ថិភាពត្រូវបានបន្សាំ អាចរកបាន និងត្រូវបានទំនាក់ទំនងយ៉ាងច្បាស់លាស់នៅក្នុងទូទាំងកម្មវិធីការងាររបស់យើង និងទៅកាន់គ្រប់បុគ្គលិក អ្នកទទួលផលព្រមទាំងសហគមន៍ពួកគាត់ ដោយប្រើភាសានិងទម្រង់ព័ត៌មានដែលពួកគាត់ងាយយល់។

SeeBeyondBorders បានប្តេជ្ញាចិត្តអនុវត្តសេចក្តីប្រកាសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីវិធានការពិសេសសម្រាប់ការការពារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ (Secretary General’s Bulletin on Special Measures for Protection from Sexual Exploitation and Sexual Abuse1) ព្រមទាំងប្តេជ្ញាអនុវត្តគោលការណ៍គាំទ្រគោលនយោបាយ DfAT របស់អូស្ត្រាលីស្តីពីការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពាន និងការបៀតបៀន (SEAH) (Australia’s DfAT Policy on sexual exploitation, abuse and harassment (SEAH)[2]) ។

[1] https://www.unhcr.org/uk/protection/operations/405ac6614/secretary-generals-bulletin-special-measures-protection-sexual-exploitation.html
[2] https://www.dfat.gov.au/sites/default/files/pseah-policy.pdf

## 4. តើអ្វីជាកិច្ចការពារសុវត្ថិភាព?

SeeBeyondBorders ទទួលស្គាល់និយមន័យកិច្ចការពារសុវត្ថិភាពថា ជាការពារសុខភាព សុខុមាលភាព និងសិទ្ធិមនុស្ស និងបង្កលក្ខណៈឱ្យពួកគេរស់នៅដោយចាកផុតពីគ្រោះថ្នាក់ ការព្រងើយកន្តើយ ការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពានផ្លូវភេទ និងការបៀតបៀនកេរ្តិ៍ខ្មាស់។

យើងយល់ថា វាមានន័យថាយើងការពារមនុស្ស រួមមានកុមារនិងមនុស្សពេញវ័យដែលមានហានិភ័យ ឱ្យចាកពីគ្រោះថ្នាក់ដែលអាចកើតឡើងតាមរយៈការប្រាស្រ័យទាក់ទងជាមួយបុគ្គលិករបស់យើង។ និយមន័យបន្ថែមទាក់ទងនឹងកិច្ចការពារសុវត្ថិភាពត្រូវបានផ្តល់ជូននៅក្នុងសទ្ទានុក្រមខាងក្រោម។

## 5. វិសាលភាពនៃការអនុវត្តគោលនយោបាយ

គោលនយោបាយនេះអនុវត្តចំពោះមនុស្សរបស់អង្គការទស្សនៈឥតព្រំដែនទាំងអស់ដែលកំណត់ថាជា:

- ក្រុមប្រឹក្សាភិបាល និងសមាជិក
- បុគ្គលិកបច្ចុប្បន្ន និងអ្នកស្ម័គ្រចិត្ត
- អ្នកប្រឹក្សាខាងក្រៅ និងអ្នកដែលមានកិច្ចសន្យា (ដោយមានប្រាក់ឈ្នួល ឬដោយស្ម័គ្រចិត្ត)
- បុគ្គលិកកិច្ចសន្យារបស់អង្គការ
- អ្នកចូលរួមក្រុមគំរោងនិងអ្នកផ្សេងទៀតដែលធ្វើការសម្រាប់ឬតាងនាមអង្គការទស្សនៈឥតព្រំដែន។

គោលនយោបាយនេះក៏អនុវត្តផងដែរចំពោះបុគ្គលផ្សេងទៀតនិងភាគីទីបីដែលជាប់ទាក់ទងជាមួយអង្គការទស្សនៈឥតព្រំដែន ក្នុងឱកាសមកមើលសកម្មភាពគម្រោងរបស់យើងបាន(ឧទាហរណ៍៖ ម្ចាស់ជំនួយ អង្គការដៃគូ អ្នកផ្តល់សេវា) បើទោះបីជាដំណើរការគ្រប់គ្រងសម្រាប់ក្រុមទាំងនេះអាចមានភាពខុសប្លែកគ្នានៅក្នុងទិដ្ឋភាពមួយចំនួនដោយសារកម្រិតការចូលរួមរបស់ពួកគេក៏ដោយ។ ដៃគូណាក៏ដោយនឹងត្រូវបានរំពឹងថានឹងប្រកាន់ខ្ជាប់នូវកាតព្វកិច្ចការពារ និង PSEAH នៃគោលនយោបាយនេះ ឬមានគោលនយោបាយផ្ទាល់អង្គភាពដែលបំពេញតាមតម្រូវការក្រមប្រតិបត្តិរបស់ ACFID (ACFID Code of Conduct)។ សូមមើលគោលនយោបាយធ្វើការជាមួយដៃគូរបស់យើងសម្រាប់ព័ត៌មានបន្ថែម។

## 6. គោលការណ៍ណែនាំសំខាន់ៗ

គោលនយោបាយកិច្ចការពារសុវត្ថិភាពរបស់អង្គការទស្សនៈឥតព្រំដែនមានគោលការណ៍ចម្បងចំនួនប្រាំមួយ៖

➢ **<u>មិនមានការអត់អោនចំពោះការរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទ និងការបៀតបៀនផ្លូវភេទ</u>**

ការរំលោភបំពានឬសកម្មភាពផ្សេងទៀតដែលបង្កគ្រោះថ្នាក់ដល់កុមារ មនុស្សវ័យក្មេង និងអ្នកទទួលផលឬអ្នកពាក់ព័ន្ធងាយរងគ្រោះ គឺមិនត្រូវបានអត់អោនជាដាច់ខាតពីអង្គការទស្សនៈឥតព្រំដែន សូម្បីតែការរក្សារូបភាពឬការចូលមើលរូបភាពអាសអាភាសកុមារ ឬការកេងប្រវ័ញ្ចផ្លូវភេទកុមារ។

ទោះវិធីនេះក៏ដោយ មិនមែនមានន័យថា គ្រាន់តែមិនមានការអត់ឱនអាចធានាការការពារពេញលេញ ឬធានាឱ្យគ្មានឧប្បត្តិហេតុសោះនោះដែរ។ ការខិតខំប្រឹងប្រែងរបស់ SeeBeyondBorders ដើម្បីធានាថាបរិយាកាសការងាររបស់យើងមានសុវត្ថិភាពសម្រាប់បុគ្គលិក អ្នកស្ម័គ្រចិត្ត អ្នកទស្សនា និងអ្នកទទួលផលទាំងអស់។ ប្រសិនបើឧបទ្ទវហេតុណាមួយកើតឡើងវានឹងត្រូវបានដោះស្រាយភ្លាមៗនិងដោយយុត្តិធម៌តាមនីតិវិធីដែលយើងបានចងក្រង។

➢ **<u>អាទិភាពនៃតម្រូវការជនរងគ្រោះ/អ្នករួចផុតពីគ្រោះថ្នាក់៖</u>**

អង្គការទស្សនៈឥតព្រំដែនប្តេជ្ញាមិនបង្កគ្រោះថ្នាក់ ហើយនឹងផ្តល់អាទិភាពដល់ជនរងគ្រោះ/អ្នករួចផុតពីគ្រោះថ្នាក់ ខណៈរក្សាភាពយុត្តិធម៌តាមនីតិវិធី។ ជនរងគ្រោះ/អ្នករួចផុតពីគ្រោះថ្នាក់ នឹងត្រូវបានទទួលការគោរព និងសេចក្តីថ្លៃថ្នូរ ឱ្យចូលរួមក្នុងដំណើរការនៃការសម្រេចចិត្ត ត្រូវបានផ្តល់ព័ត៌មានពេញលេញ និងផ្តល់ជូននូវព័ត៌មានពាក់ព័ន្ធទាំងអស់តាមដែលអាចធ្វើបាន និងអាចត្រូវបញ្ជូនសម្រាប់សេវាគាំទ្របន្ថែម/អ្នកជំនាញគាំទ្រដទៃទៀត។ អង្គការទស្សនៈឥតព្រំដែនទទួលស្គាល់ថាកុមារខ្លះនិងមនុស្សពេញវ័យដែលមានហានិភ័យដូចជាជនពិការ ឬរស់នៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយគ្រោះមហន្តរាយ (ដោយធម្មជាតិ ឬជម្លោះ) ពួកគាត់មានភាពងាយរងគ្រោះជាពិសេស ដែលត្រូវតែផ្តល់អាទិភាពសម្រាប់ពួកគាត់។

➢ **<u>ភាពរឹងមាំក្នុងការដឹកនាំ និង ទំនួលខុសត្រូវរួមគ្នាចំពោះការការពារអ្នកទទួលផលជាកុមារនិងជនងាយរងគ្រោះ៖</u>**

ដើម្បីគ្រប់គ្រងហានិភ័យចំពោះកុមារនិងជនងាយរងគ្រោះប្រកបដោយប្រសិទ្ធភាព អង្គការទស្សនៈឥតព្រំដែនតម្រូវឱ្យមានការគាំទ្រនិងការសហការយ៉ាងសកម្មពីបុគ្គលិកទាំងអស់។ ថ្នាក់ដឹកនាំរបស់យើងប្តេជ្ញាចិត្តក្នុងការធ្វើគំរូភាព ប្រកបដោយបរិយាបន្ន សមានចិត្ត និងធានាថាអ្នកណាដែលជាជនរងគ្រោះ ឬបានឃើញហេតុការណ៍ណាមួយ ត្រូវបានគាំទ្រ និងមានអារម្មណ៍ថាមានសុវត្ថិភាពក្នុងការធ្វើរបាយការណ៍។ យើងប្តេជ្ញាបណ្តុះបណ្តាលនិងអភិវឌ្ឍបុគ្គលិករបស់យើង ដើម្បីធានាថាអ្នករាល់គ្នាដឹងពីការទទួលខុសត្រូវរបស់ខ្លួនចំពោះការការពារសុវត្ថិភាព និងការការពារការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពាននិងការបៀតបៀនផ្លូវភេទ។ បុគ្គលិករបស់អង្គការទស្សនៈឥតព្រំដែន ត្រូវតែគោរពតាមគោលនយោបាយនេះហើយនឹងទទួលខុសត្រូវចំពោះការប្រតិបត្តិវាជាចាំបាច់។

➢ **ការប្រើវិធីសាស្ត្រគ្រប់គ្រងហានិភ័យ**

ការគ្រប់គ្រងដោយប្រយ័ត្នប្រយែង អាចកាត់បន្ថយអត្រា នៃការកេងប្រវ័ញ្ច ការរំលោភបំពាន និងការយាយីដល់កុមារ និងអ្នកទទួលផលដែលងាយរងគ្រោះដែលទាក់ទងនឹងសកម្មភាពអភិវឌ្ឍន៍នានា។ គោលនយោបាយនេះ បង្ហាញពីយុទ្ធសាស្ត្រក្នុងការកាត់បន្ថយហានិភ័យដែលអាចកើតមានចំពោះកុមារនិងអ្នកទទួលផលដែលងាយរងគ្រោះ ហើយយើងប្ដេជ្ញាពិនិត្យឡើងវិញនូវហានិភ័យទាំងនោះជាប្រចាំ រួមជាមួយគោលនយោបាយ ដំណើរការ និងនីតិវិធីពាក់ព័ន្ធ ដើម្បីធានាវាឆ្លើយតបតាមគោលបំណងនេះ។ យើងបណ្ដុះបណ្ដាលបុគ្គលិក អ្នកស្ម័គ្រចិត្ត និងអ្នកទស្សនកិច្ចរបស់យើង ឱ្យទទួលស្គាល់ការការពារសុវត្ថិភាព និងកំណត់អត្តសញ្ញាណ SEAH និងធ្វើតាមនីតិវិធីរាយការណ៍របស់យើង ដែលមានចងក្រងជាឯកសារនៅក្នុងគោលនយោបាយនេះ ក៏ដូចជាគោលនយោបាយការពារកុមារ និងជនងាយរងគ្រោះរបស់យើង និងគោលនយោបាយដោះស្រាយពាក្យបណ្ដឹងនិងការឆ្លើយតប )Complaints and Feedback Handling Policy (របស់យើង។ យើងប្ដេជ្ញាថា នឹងរាយការណ៍បន្ត ដោយធានាថាឧប្បត្តិហេតុ ឬឧបទ្ទវហេតុដែលគួរឱ្យសង្ស័យនៃ SEAH ត្រូវបានរាយការណ៍ទៅអាជ្ញាធរមូលដ្ឋាន ដែលសមស្របបំផុតក៏ដូចជា អាជ្ញាធរខាងក្រៅដែលពាក់ព័ន្ធដូចជានាយកដ្ឋានកិច្ចការបរទេសនិងពាណិជ្ជកម្ម )DfAT) នៅក្នុងប្រទេសអូស្ត្រាលី និងការិយាល័យ Foreign, Commonwealth and Development Office (FCDO) នៅចក្រភពអង់គ្លេស។

➢ **វិសមភាពយេនឌ័រនិងអតុល្យភាពអំណាចត្រូវបានឃ្លាំមើលដោយផ្ចិតផ្ចង់**

អង្គការទស្សនៈឥតព្រំដែនទទួលស្គាល់ថាខណៈដែលជនរងគ្រោះអ្នកដ/ែលរួចផុតពី SEAH ភាគច្រើនជាស្ត្រីនិងក្មេងស្រី ហើយជនដៃដល់ជាបុរសនិងក្មេងប្រុស។ នេះមិនមែនគ្រប់ករណីនោះទេ។ មានអតុល្យភាពអំណាចផ្សេងទៀតដែលអាចនាំឱ្យមាន SEAH និងកង្វល់ផ្សេងទៀតដែលត្រូវការពារ។ អតុល្យភាពអំណាចដូចជាពូជសាសន៍ សញ្ជាតិ/យេនឌ័រ សមត្ថភាព សាវតាសេដ្ឋកិច្ចសង្គម អ្នកអនុវត្តកម្មវិធីជាមួយអ្នកទទួលផល អតីតភាពការងារនៅកន្លែងធ្វើការ ទាំងអស់នេះសុទ្ធតែអាចជះឥទ្ធិពលនិងនាំឱ្យមាន SEAH ហើយវារឹតតែបន្ថែមទម្ងន់ហានិភ័យប្រសិនបើមានអតុល្យភាពអំណាចច្រើនជាងមួយក្នុងពេលតែមួយ ឧទាហរណ៍អ្នកទទួលផលជាស្ត្រីដែលមានពិការភាពប្រឈមនឹងបុគ្គលិកប្រុស។ អតុល្យភាពអំណាចនឹងត្រូវកាត់បន្ថយតាមដែលអាចធ្វើទៅបាន ប៉ុន្តែយើងទទួលស្គាល់ថាវាមិនមែនតែងតែអាចលុបបំបាត់ និងគ្រប់គ្រងបានទាំងស្រុងនោះទេ ដូច្នេះយើងគិតគូរយ៉ាងសកម្មក្នុងការបង្ការហានិភ័យពាក់ព័ន្ធតាមរយៈការបង្កើនការយល់ដឹង និងការបណ្ដុះបណ្ដាលក្នុងចំណោមបុគ្គលិកនិងសហគមន៍ដែលយើងធ្វើការ។

➢ <u>កាតព្វកិច្ចដែលត្រូវយកចិត្តទុកដាក់:</u>

អង្គការទស្សនៈឥតព្រំដែនទទួលស្គាល់ទំនួលខុសត្រូវជាករណីយកិច្ចរបស់ខ្លួនដែលត្រូវយកចិត្តទុកដាក់ ហើយអនុវត្តគ្រប់ជំហានដែលសមស្របដើម្បីការពារសុវត្ថិភាពកុមារនិងជនងាយរងគ្រោះនៅក្នុង

កម្មវិធីរបស់ខ្លួន។

## 7. និយមន័យ

### មនុស្សពេញវ័យដែលមានហានិភ័យ

ពេលខ្លះក៏ត្រូវបានហៅថាមនុស្សពេញវ័យដែលងាយរងគ្រោះដែរ។ បុគ្គលដែលមានតម្រូវការជំនួយឬថែទាំចាំបាច់ ដោយហេតុផលពិការភាពផ្លូវចិត្ត ឬអាយុ ឬជំងឺផ្សេងៗ ឬដែលមិនអាចមើលថែខ្លួនឯងបាន ឬមិនអាចការពារខ្លួនគាត់ពីគ្រោះថ្នាក់ ឬពីការកេងប្រវ័ញ្ច។

### អ្នកទទួលផលពីការជួយ

នរណាម្នាក់ដែលទទួលផលឬសេវាកម្មផ្ទាល់ពីកម្មវិធីរបស់អង្គការទស្សនៈឥតព្រំដែន។ សូមចំណាំថាការបំពានសិទ្ធិអំណាចក៏អាចកើតឡើងទៅលើសហគមន៍ដែលអង្គការទស្សនៈឥតព្រំដែនធ្វើការជាមួយ ហើយក៏អាចរួមបញ្ចូលការកេងប្រវ័ញ្ចតាមរយៈសិទ្ធិអំណាចឥទ្ធិពលតួនាទី។

### កុមារ

បុគ្គលដែលមានអាយុក្រោម 18ឆ្នាំ

### គ្រោះថ្នាក់

ការរំលោភបំពានផ្លូវចិត្ត, រាងកាយ និងការរំលោភបំពានផ្សេងទៀតលើសិទ្ធិរបស់បុគ្គល

### គ្រោះថ្នាក់ផ្លូវចិត្ត

ការរំលោភបំពានផ្លូវចិត្តឬផ្លូវអារម្មណ៍ដែលរួមបញ្ចូល (ប៉ុន្តែមិនកំណត់) ការធ្វើអោយអាម៉ាស់មុខនិងការធ្វើអោយខូចកេរ្តិ៍ឈ្មោះដូចជាការហៅឈ្មោះអាក្រក់ ការរិះគន់, ការបន្ទាបបន្ថោក, ការធ្វើអោយអាម៉ាស់, ទណ្ឌកម្មដោយការបង្ខាំង និងដាក់ឱ្យនៅដាច់ដោយឡែក។

### កិច្ចការពារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពាន និងការបៀតបៀន (PSEAH)

ពាក្យនេះត្រូវបានប្រើប្រាស់ដោយសហគមន៍មនុស្សធម៌និងអភិវឌ្ឍន៍ ដើម្បីសំដៅទៅលើការការពារពីការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពាន និងការបៀតបៀនផ្លូវភេទ លើក្រុមមនុស្សដែលរងផលប៉ះពាល់ដោយបុគ្គលិក ឬមនុស្សពាក់ព័ន្ធ។ ពាក្យនេះទទួលបានពីសេចក្តីប្រកាសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ស្តីពីវិធានការពិសេសដើម្បីការពារការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ (ST/SGB/2003/13)។

### កិច្ចការពារសុវត្ថិភាព

កិច្ចការពារសុវត្ថិភាពមានន័យថាការការពារសុខភាព សុខុមាលភាពមនុស្ស និងសិទ្ធិមនុស្ស និង អនុញ្ញាតឱ្យពួកគេរស់នៅដោយរួចផុតពីគ្រោះថ្នាក់ ការរំលោភបំពាន និងការបោះបង់ចោល។

នៅក្នុងវិស័យរបស់យើង យើងយល់ថាវាមានន័យថាការការពារមនុស្ស រួមទាំងកុមារនិងមនុស្សពេញវ័យដែលកំពុងជួបគ្រោះថ្នាក់ពីផលប៉ះពាល់ដែលកើតឡើងតាមរយៈការទាក់ទងជាមួយបុគ្គលិក អ្នកស្ម័គ្រចិត្ត ភ្ញៀវ ឬកម្មវិធីរបស់យើង។ និយមន័យរបស់ម្ចាស់ជំនួយមួយចែងដូចខាងក្រោម៖

កិច្ចការពារសុវត្ថិភាពមានន័យថាការចាត់វិធានការសមស្របទាំងអស់ដើម្បីបង្ការគ្រោះថ្នាក់ជាពិសេសការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពាន និងការរំខានពីការកើតមានឡើង ដើម្បីការពារមនុស្សជាពិសេសមនុស្សពេញវ័យដែលងាយរងគ្រោះនិងកុមារពីគ្រោះថ្នាក់នោះ និងដើម្បីឆ្លើយតបឱ្យបានត្រឹមត្រូវនៅពេលដែលមានគ្រោះថ្នាក់កើតឡើង។

និយមន័យនេះគូសបញ្ជាក់តម្លៃនិងគោលការណ៍របស់យើង ហើយបង្កើតវប្បធម៌របស់យើង។ វាចង្អុលបង្ហាញការយកចិត្តទុកដាក់ជាក់លាក់ក្នុងការបង្ការនិងឆ្លើយតបទៅនឹងគ្រោះថ្នាក់ពីការរំលោភបំពានអំណាច, ភាពជឿជាក់ឬភាពងាយរងគ្រោះណាមួយដែលអាចកើតមានជាក់ស្តែង ទំនងជានឹងកើតឡើង ឬមានការប៉ុនប៉ង ជាពិសេសចំពោះគោលបំណងផ្លូវភេទ។

កិច្ចការពារសុវត្ថិភាពត្រូវបានអនុវត្តជាប់លាប់និងដោយគ្មានករណីលើកលែងនៅទូទាំងកម្មវិធី, ដៃគូរបស់យើង, បុគ្គលិក, អ្នកស្ម័គ្រចិត្ត និងភ្ញៀវ។ វាទាមទារអោយមានការកំណត់មុខសញ្ញាហានិភ័យ ការបង្កា និងការការពារប្រឆាំងនឹងហានិភ័យទាំងអស់ ការកេងប្រវ័ញ្ច និងការរំលោភបំពាន និង មានប្រព័ន្ធគណនេយ្យភាពនិងតម្លាភាពពេញលេញដើម្បីឆ្លើយតប ការរាយការណ៍និងការរៀនសូត្រនៅពេលមានហានិភ័យកើតឡើង។ ប្រព័ន្ធទាំងនោះត្រូវផ្តោតលើអ្នកប្រឹងរស់រានមានជីវិតជាចម្បង ហើយក៏ការពារអ្នកដែលត្រូវបានគេចោទប្រកាន់រហូតដល់ភស្តុតាងពិរុទ្ធត្រូវបានប្រកាសផងដែរ។

កិច្ចការពារសុវត្ថិភាព ផ្តោតការយកចិត្តទុកដាក់លើអ្នកទទួលផល ជនរងគ្រោះ និងអ្នកដែលរួចជីវិតពីការរងគ្រោះជាចំណុចកណ្តាលនៃគ្រប់អ្វីដែលយើងធ្វើ។

**ការរំលោភបំពានផ្លូវភេទ**

ពាក្យថា "ការរំលោភបំពានផ្លូវភេទ" មានន័យថាការរំលោភបំពានលើរាងកាយជាក់ស្តែងឬដោយការគំរាមកំហែងផ្លូវកាយនៃធម្មជាតិផ្លូវភេទ មិនថាដោយប្រើកម្លាំង ឬក្រោមលក្ខខណ្ឌមិនស្មើភាព ឬការបង្ខិត

បង្ខំ[3]។ វាគ្របដណ្តប់បទល្មើសផ្លូវភេទ រួមមានជាអាទិ៍៖ ការប៉ុនប៉ងរំលោភសេពសន្ថវៈ (ដែលរួមបញ្ចូលទាំងការប៉ុនប៉ងបង្ខំនរណាម្នាក់ឱ្យរួមភេទតាមផ្លូវមាត់) និងការរំលោភបំពានផ្លូវភេទ (ដែលរួមបញ្ចូលទាំងការថើប និងការប៉ះដោយមិនមានការព្រមព្រៀង) ។ រាល់សកម្មភាពទាក់ទងផ្លូវភេទជាមួយកុមារត្រូវបានចាត់ទុកថាជាការរំលោភបំពានផ្លូវភេទ។

**ការកេងប្រវ័ញ្ចផ្លូវភេទ**

ពាក្យថា "ការកេងប្រវ័ញ្ចផ្លូវភេទ" មានន័យថាការរំលោភបំពានជាក់ស្តែងឬប៉ុនប៉ងរំលោភ ក្នុងស្ថានភាពកេងចំណេញលើភាពងាយរងគ្រោះ អតុល្យភាពកំលាំង ឬបំពានការជឿទុកចិត្ត សម្រាប់គោលបំណងផ្លូវភេទ ដោយរាប់បញ្ចូល(ប៉ុន្តែមិនកំណត់)ទាំងការកេងចំណេញជាប្រាក់ ឋានៈសង្គម ឬចំណេញផ្នែកនយោបាយ បានពីការកេងប្រវ័ញ្ចផ្លូវភេទលើអ្នកដទៃ[4]។ និយមន័យនេះរួមបញ្ចូលការជួញដូរមនុស្សនិងទាសភាពសម័យទំនើប។

**ការបៀតបៀនផ្លូវភេទ**

ការបៀតបៀនផ្លូវភេទ ពាក់ព័ន្ធទៅនឹងទំនោរឈានទៅដល់ផ្លូវភេទដែលមិនត្រូវបានស្វាគមន៍ ការស្នើសុំការអនុគ្រោះខាងផ្លូវភេទ ជាពាក្យសំដី ឬមិនមែនជាពាក្យសំដី ឬកាយវិការដែលមានចរិតលក្ខណៈផ្លូវភេទ ឬអាកប្បកិរិយាផ្សេងទៀតដែលមានលក្ខណៈផ្លូវភេទដែលអាចត្រូវបានរំពឹងទុក ឬយល់ឃើញថាបង្កឱ្យមានបទល្មើស ឬធ្វើឱ្យអាម៉ាស់មុខជាដើម។ នេះរួមបញ្ចូលទាំងការយាយីផ្លូវភេទ ដែលត្រូវបានធ្វើឡើង តាមអ៊ីនធឺណិត ឬតាមរយៈបណ្តាញសង្គម។

ការបៀតបៀនផ្លូវភេទមិនមានអ្វីទាក់ទង នឹងការទាក់ទាញគ្នាទៅវិញទៅមក ឬការយល់ព្រមក្នុងមេត្រីភាពមិនថាផ្លូវភេទ ឬរឿងផ្សេងទៀតឡើយ។ ការបៀតបៀនផ្លូវភេទវិញគឺខុសច្បាប់ ទោះមុនត្រូវបានជួលឱ្យធ្វើការ និងនៅកន្លែងធ្វើការ។ កន្លែងធ្វើការ រួមបញ្ចូលទាំងកន្លែង ដែលមនុស្សម្នាក់ទៅ ក្នុងគោលបំណងបំពេញមុខងារណាមួយ ទាក់ទងនឹងការងាររបស់គាត់ និងអាចពង្រីកមុខងារសង្គមផងដែរ។

ឧទាហរណ៍ខ្លះនៃការបៀតបៀនផ្លូវភេទរួមមាន៖

- ការទាមទារដោយទទូចនិងដោយមិនត្រូវបានស្វាគមន៍ ឬការដាក់សម្ពាធលើទំនោរខាងផ្លូវភេទទោះដោយស្ងាត់ៗ មានការទម្លាយឱ្យដឹងជាសាធារណៈក្តី។
- ការសម្លក់ ឬសម្លឹងមើលបុគ្គលម្នាក់ ឬផ្នែកណាមួយនៃរាងកាយរបស់គេក្នុងន័យចំណង់ផ្លូវភេទ
- ការទទះស្រាលៗ ការក្តិច ឬការប៉ះដោយមិនត្រូវបានស្វាគន៍ ឬការស្និទ្ធស្នាលដែលមិនចាំបាច់ ដូចជាការបបោសអង្អែលដោយមិនចាំបាច់ទៅលើបុគ្គលណាម្នាក់
- ការផ្តល់យោបល់ផ្លូវភេទដែលមិនចង់បាន

[3] https://www.unhcr.org/uk/protection/operations/405ac6614/secretary-generals-bulletin-special-measures-protection-sexual-exploitation.html
[4] Ibid

- មតិយោបល់ ឬសំណួរដែលមើលងាយ អំពីរូបរាងកាយរបស់មនុស្សម្នាក់ ការស្លៀកពាក់ ឬជីវិតឯកជន
- របស់អាសអាភាសជារូបថត ឬផ្ទាំងរូបភាព ឬការដាក់លើអេក្រង់ (ជាពាក្យនិងរូបភាព)
- ទង្វើបែបទំនោរទៅរកផ្លូវភេទតាមរយៈការនិយាយទូរស័ព្ទ, អក្សរ, សារ, អ៊ីមែលឬសារជាសំលេង;
- ការចំអកលេងសើចដូចជារឿងកំប្លែងឬការផ្តល់យោបល់កំប្លែងបែបមិនសមរម្យ
- ការប្រើសម្តីលេបខាយបែបផ្លូវភេទ រួមទាំងសំដីញុះញង់ផ្លូវភេទ ការផ្តល់យោបល់ ឬការប្រមាថអំពីរូបរាងរាងកាយរបស់បុគ្គល ការសន្និដ្ឋានអំពីសីលធម៌ផ្លូវភេទ ឬរឿងនិទាននៃការសម្តែងផ្លូវភេទ
- ការស្នើសុំរួមភេទ;
- ការប្រមាថឬការជេរប្រមាថផ្អែកលើភេទ
- ទំនាក់ទំនងរាងកាយ(កាយវិការ)ដែលបង្ហាញពីរឿងផ្លូវភេទ

ឧទាហរហ៍ទាំងអស់ខាងលើគឺមិនទាន់អស់ត្រឹមនោះទេ។

**អ្នករួចផុតពីគ្រោះថ្នាក់**

មនុស្សដែលត្រូវបានគេរំលោភបំពានឬកេងប្រវ័ញ្ច ។ ពាក្យថា "អ្នករួចផុតពីគ្រោះថ្នាក់" ជារឿយៗត្រូវបានគេជ្រើសប្រើជំនួសពាក្យ "ជនរងគ្រោះ" ពីព្រោះវាបង្ហាញពីកម្លាំង ភាពស៊ូនិងសមត្ថភាព ឱ្យរួចផុតពីគ្រោះថ្នាក់។ ទោះយ៉ាងនេះក៏ដោយ វាជាជម្រើសរបស់បុគ្គលម្នាក់ៗ ក្នុងការកំណត់ស្ថានភាពខ្លួនឯង។

**ការដោះដូរដើម្បីមេត្រីភេទ**

ការផ្តោះប្តូរជាប្រាក់ ការងារ ទំនិញ សេវាកម្ម ឬអត្ថប្រយោជន៍ផ្សេងទៀត សម្រាប់ជាថ្នូរដើម្បីបានការរួមភេទ រួមទាំងចំណង់ចំណូលចិត្តផ្លូវភេទផងដែរ។

**មនុស្សវ័យក្មេង**

អង្គការសហប្រជាជាតិបានកំណត់និយមន័យមនុស្សវ័យក្មេង (រួមបញ្ចូលទាំងបុរសវ័យក្មេង-នារីវ័យក្មេង និងមនុស្សដែលមានអត្តសញ្ញាណយេនឌ័រផ្សេងទៀតវ័យក្មេង) ជាមនុស្សទាំងឡាយដែលមានអាយុពី ១៥ ទៅ ២៤ ឆ្នាំ។ ក្រុមនេះលាតសន្ធឹងគ្របដណ្តប់លើក្រុម" កុមារ"" វ័យជំទង់" និង" មនុស្សធំ" ប៉ុន្តែចាត់ទុកមនុស្សវ័យក្មេងថាមានតម្រូវការការពារពិសេស ដែលតម្រូវឱ្យមានការពិចារណាតម្រូវការដោយឡែកពីកុមារវ័យក្មេងនិងមនុស្សចាស់។

## 8. <u>ការបង្ការទប់ស្កាត់</u>

***ទំនួលខុសត្រូវរបស់អង្គការទស្សនៈឥតព្រំដែននិងស្តង់ដារប្រតិបត្តិ***

អង្គការទស្សនៈឥតព្រំដែននឹង៖

- ធានាថាគ្រប់បុគ្គលិក អ្នកស្ម័គ្រចិត្តនិងភ្ញៀវទាំងអស់មានលទ្ធភាពទទួលបាន ចំណែកជាមួយ និងបានយល់អំពីសិទ្ធិ និងទំនួលខុសត្រូវរបស់ពួកគេនៅក្នុងគោលនយោបាយនេះ
- រៀបចំ និងអនុវត្តកម្មវិធីនិងសកម្មភាពទាំងអស់របស់ខ្លួន ក្នុងរបៀបដែលការពារមនុស្សពីហានិភ័យនៃគ្រោះថ្នាក់ដែលអាចកើតមានឡើងកើតពីទំនាក់ទំនងរបស់ពួកគេជាមួយនឹងអង្គការទស្សនៈឥតព្រំដែន។ នេះរួមបញ្ចូលទាំងវិធីដែលព័ត៌មានអំពីបុគ្គលនៅក្នុងកម្មវិធីរបស់យើងត្រូវបានប្រមូលចងក្រង រក្សាទុក និងទំនាក់ទំនងប្រាប់គ្នា
- ធានាថាកិច្ចការពារសុវត្ថិភាព និងការការពារការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពាន និងការបៀតបៀនផ្លូវភេទ ត្រូវបានគេពិចារណានៅក្នុងដំណើរការវាយតម្លៃហានិភ័យគ្រប់គម្រោង ក៏ដូចជាលើការវាយតម្លៃហានិភ័យរបស់អង្គការ និងយុទ្ធសាស្ត្របន្ថយហានិភ័យសមស្រប ត្រូវបានអនុវត្តស្របតាមស្តង់ដារអប្បបរមារបស់ DfAT (DfAT's Minimum Standards[5]);
- អនុវត្តនីតិវិធីការពារយ៉ាងតឹងរឹង ដូចដែលមានចែងនៅក្នុងសៀវភៅណែនាំធនធានមនុស្ស របស់យើងនៅពេលជ្រើសរើស ការគ្រប់គ្រង ការពង្រាយបុគ្គលិក និងអ្នកស្ម័គ្រចិត្ត។ នេះរួមមានការត្រួតពិនិត្យសេចក្តី/អ្នកធានា និងលិខិតបញ្ជាក់របស់ប៉ូលីស
- ធានាថាបុគ្គលិក ទទួលបានការបណ្តុះបណ្តាល អំពីកិច្ចការពារសុវត្ថិភាព និង PSEAH ក្នុងកម្រិតមួយដែលសមស្រប នឹងតួនាទីរបស់ពួកគេនៅក្នុងអង្គការ។
- ហាមឃាត់រាល់ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពាន ឬការបៀតបៀន។
- ទំនាក់ទំនងយ៉ាងច្បាស់លាស់ឱ្យស្គាល់អ្នកទទួលខុសត្រូវលើកិច្ចការពារសុវត្ថិភាពរបស់យើងជានរណា ព្រមទាំងរបៀបរាយការណ៍អំពីឧប្បត្តិហេតុ ឬកង្វល់ដែលទាក់ទងសុវត្ថិភាព
- បង្ហាញយ៉ាងច្បាស់ដល់បុគ្គលិកអំពី របៀបរាយការណ៍ អំពីឧប្បត្តិហេតុ ឬការសង្ស័យទាក់ទងនិង SEAH
- តាមដានលើរបាយការណ៍ស្តីពីបញ្ហាកិច្ចការពារសុវត្ថិភាព ឬក៏ SEAH និងយោងទៅតាមនីតិវិធីត្រឹមត្រូវ។

### *ការទទួលខុសត្រូវរបស់បុគ្គលិកនិងស្តង់ដានៃការប្រតិបត្តិ*

### <u>កិច្ចការពារសុវត្ថិភាពកុមារ</u>

បុគ្គលិកអង្គការទស្សនៈឥតព្រំដែន អ្នកស្ម័គ្រចិត្ត និងភ្ញៀវមិនត្រូវ៖

- ចូលរួមក្នុងសកម្មភាពរួមភេទជាមួយអ្នកដែលមានអាយុក្រោម 18 ឆ្នាំជាដាច់ខាត
- រំលោភបំពានផ្លូវភេទឬកេងប្រវ័ញ្ចកុមារ
- បង្កឱកាសឱ្យកុមាររងការរំលោភបំពានរាងកាយ អារម្មណ៍ឬផ្លូវចិត្ត ឬការមិនយកចិត្តទុកដាក់
- ចូលរួមក្នុងសកម្មភាពកេងប្រវ័ញ្ចលើពាណិជ្ជកម្មជាមួយកុមារ រួមទាំងពលកម្មកុមារឬការជួញដូរ។

[5] www.dfat.gov.uk/pseah

## កិច្ចការពារសុវត្ថិភាពមនុស្សពេញវ័យ

បុគ្គលិកអង្គការទស្សនៈឥតព្រំដែន អ្នកស្ម័គ្រចិត្ត និងភ្ញៀវមិនត្រូវ៖

- រំលោភបំពានផ្លូវភេទ ឬកេងប្រវ័ញ្ចម ឬបៀតបៀនផ្លូវភេទមនុស្សពេញវ័យដែលកំពុងជួបគ្រោះថ្នាក់ និងមនុស្សដទៃទៀត
- ដាក់កម្រិតលើមនុស្សពេញវ័យដែលកំពុងជួបគ្រោះថ្នាក់ ឱ្យស្ថិតក្រោមស្ថានភាពត្រូវបានរំលោភបំពានរាងកាយ អារម្មណ៍ឬផ្លូវចិត្ត ឬការមិនយកចិត្តទុកដាក់។

## ការការពារពី ការរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទ និងការបៀតបៀន

បុគ្គលិកអង្គការទស្សនៈឥតព្រំដែន អ្នកស្ម័គ្រចិត្ត និងភ្ញៀវមិនត្រូវ៖

- ផ្តោះប្តូរប្រាក់ ការងារ ទំនិញឬសេវាកម្មសម្រាប់ជាថ្នូរបានសកម្មភាពផ្លូវភេទ។ នេះរួមបញ្ចូលទាំងការផ្តោះប្តូរដែលត្រូវបានស្នើសុំដោយអ្នកទទួលផល។
- មានទំនាក់ទំនងផ្លូវភេទជាមួយអ្នកទទួលផលពីជំនួយ ដោយសារពួកគេត្រូវបានផ្អែកលើសក្តានុពលអំណាចមិនស្មើភាព។

លើសពីនេះទៅទៀត បុគ្គលិកអង្គការទស្សនៈឥតព្រំដែន អ្នកស្ម័គ្រចិត្តនិងភ្ញៀវមានកាតព្វកិច្ច៖

- រួមចំណែកក្នុងការបង្កើតនិងថែរក្សាបរិស្ថានដែលបង្ការការរំលោភបំពានកិច្ចការពារសុវត្ថិភាព និងលើកកម្ពស់ការអនុវត្តគោលនយោបាយកិច្ចការពារសុវត្ថិភាព។
- រាយការណ៍អំពីការព្រួយបារម្ភឬការសង្ស័យណាមួយដែលទាក់ទងនឹងការរំលោភបំពានកិច្ចការពារសុវត្ថិភាព ឬSEAH ប្រព្រឹត្តដោយបុគ្គលិករបស់អង្គការទស្សនៈឥតព្រំដែន អ្នកស្ម័គ្រចិត្ត ឬភ្ញៀវទៅកាន់បុគ្គលិកដែលសមស្របតាមនីតិវិធីរាយការណ៍។
- ប្រកាន់ខ្ជាប់នូវក្រមសីលធម៌របស់អង្គការ ដែលកំណត់នូវការរំពឹងទុកទូលំទូលាយទាក់ទងនឹងការការពារ និងស្តង់ដារនៃអាកប្បកិរិយារំពឹងទុក។
- ការខកខានមិនអនុវត្តស្តង់ដារប្រតិបត្តិដែលមានចែងក្នុងគោលការណ៍នេះ គឺជាមូលដ្ឋាននៃការដាក់វិន័យ អាចចាត់ទុកថាជាការប្រព្រឹត្តកំហុសសរុប/ធ្ងន់ធ្ងរ និងអាចឈានដល់ការបញ្ឈប់ការងារ។ រាល់ការប្រព្រឹត្តបទឧក្រិដ្ឋណាមួយ នឹងត្រូវបានរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងប្រទេសដែលយើងធ្វើការ និងស្របតាមបំណងរបស់ជនរងគ្រោះ/អ្នកដែលរួចផុតពីគ្រោះថ្នាក់ ក្នុងលក្ខខណ្ឌសុវត្ថិភាពជាក់ស្តែង។

## 9. ការធ្វើរបាយការណ៍

អង្គការទស្សនៈគតព្រំដែននឹងធានាថាមធ្យោបាយដែលមានសុវត្ថិភាព សមស្រប ភាពអាចយកបាន និងការរក្សាការសម្ងាត់ក្នុងការរាយការណ៍ពីបញ្ហាកិច្ចការពារសុវត្ថិភាព និង SEAH ដែលត្រូវបានផ្តល់ជូនដល់បុគ្គលិក, អ្នកស្ម័គ្រចិត្ត, ភ្ញៀវនិងសហគមន៍ដែលយើងធ្វើការជាមួយ។

បុគ្គលិកណាដែលរាយការណ៍អំពីការព្រួយបារម្ភឬបណ្តឹងតាមរយៈខ្សែបញ្ញាញផ្លូវការសម្រាប់បណ្តឹង (ឬតាមរយៈផ្សេងពីនេះក៏ដោយ) នឹងត្រូវបានការពារដោយ ៗគោលនយោបាយរាយការណ៍ជាសំងាត់ Whistleblowing Policy របស់អង្គការទស្សនៈគតព្រំដែន។

អង្គការទស្សនៈគតព្រំដែនក៏នឹងទទួលយកពាក្យបណ្តឹងពីប្រភពខាងក្រៅដូចជាសមាជិកសាធារណៈជនដៃគូរ និងស្ថាប័នផ្លូវការ។ របាយការណ៍អនាមិកក៏នឹងត្រូវបានទទួលយកដែរ .. យើងនឹងធានាថារបាយការណ៍ទាំងអស់ ត្រូវបានរក្សាការសម្ងាត់ ទោះបីជាអំពើឧក្រិដ្ឋកម្មណាមួយនឹងត្រូវបញ្ជូនទៅអាជ្ញាធរពាក់ព័ន្ធក៏ដោយ។

## *របៀបរាយការណ៍អំពីបញ្ហាទាក់ទងនឹងកិច្ចការពារសុវត្ថិភាព*

### មនុស្សក្នុងអង្គការ

បុគ្គលិកដែលមានពាក្យបណ្តឹង ឬការព្រួយបារម្ភទាក់ទងនឹងកិច្ចការពារសុវត្ថិភាព ការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពាន ឬការបៀតបៀន (SEAH) គួរតែរាយការណ៍វាភ្លាមៗទៅកាន់ប្រធានផ្នែកកិច្ចការពារសុវត្ថិភាពឬអ្នកគ្រប់គ្រងផ្ទាល់របស់ពួកគេ។ ការរាយការណ៍នេះ អាចធ្វើតាមរយៈ ផ្ទាល់មាត់ ពេលជួបផ្ទាល់ ឬតាមទូរស័ព្ទ អ៊ីម៉ែល ឬក៏សំបុត្រ។ ប្រសិនបើបុគ្គលិកមិនមានអារម្មណ៍សុខស្រួលក្នុងការរាយការណ៍ទៅប្រធានផ្នែកកិច្ចការពារសុវត្ថិភាពឬអ្នកគ្រប់គ្រងផ្ទាល់របស់ខ្លួន (ឧទាហរណ៍ប្រសិនបើពួកគេមានអារម្មណ៍ថារបាយការណ៍នេះនឹងមិនត្រូវបានយកចិត្តទុកដាក់ម៉ត់ចត់ទេឬបើបុគ្គលនោះជាប់ពាក់ព័ន្ធក្នុងបញ្ហានោះ) ពួកគេអាចរាយការណ៍ទៅបុគ្គលិកដែលមានសមត្ថកិច្ចផ្សេងទៀត ។ ឧទាហរណ៍ អ្នកទាំងនោះអាចជាប្រធានគ្រប់គ្រងផ្នែកធនធានមនុស្ស ឬជាសមាជិកនៃក្រុមអ្នកដឹកនាំ ឬអ្នកគ្រប់គ្រងផ្សេងទៀតនៅការិយាល័យប្រចាំប្រទេសមួយផ្សេងទៀត។

បុគ្គលិករបស់ SeeBeyondBorders ក៏អាចរាយការណ៍ អំពីការព្រួយបារម្ភផងដែរ បន្ទាប់ពីដំណើរការដែលបានរៀបរាប់នៅក្នុងគោលនយោបាយ Whistleblowing Policy (សូមមើលគោលនយោបាយពាក់ព័ន្ធ) ។

### អ្នកស្ម័គ្រចិត្ត អ្នកទស្សនកិច្ចនិងសហគមន៍

អ្នកស្ម័គ្រចិត្ត អ្នកទស្សនកិច្ច និងសហគមន៍ដែលយើងធ្វើការជាមួយ គួរតែរាយការណ៍អំពីការការពារឬកង្វល់របស់ SEAH ទៅជនបង្គោលការពារសុវត្ថិភាព នៅក្នុងប្រទេសរបស់ពួកគេ (សូមមើលឧបសម្ព័ន្ធ A សម្រាប់លេខទូរស័ព្ទ) ឬអ៊ីមែល safeguarding@seebeyondborders.org ។ ម៉្យាងទៀតអ្នកស្ម័គ្រចិត្ត

អ្នកទស្សនកិច្ចនិងអ្នកទទួលផល អាចរាយការណ៍អំពីកង្វល់ទៅកាន់បុគ្គលិក SeeBeyondBorders ផ្សេងទៀត ដែលនឹងយកការព្រួយបារម្ភនេះទៅកាន់មនុស្សដែលសមស្របបំផុត។

**អាជ្ញាធរខាងក្រៅ**

ករណីសង្ស័យ ឬចោទប្រកាន់ទាំងអស់ស្តីពី SEAH ទាក់ទងនឹងកម្មវិធីបានមូលនិធិ DfAT នឹងត្រូវរាយការណ៍ទៅ DfAT នៅអូស្ត្រាលីដោយ SeeBeyondBorders ។ ករណីនឹងត្រូវបានរាយការណ៍ ដោយប្រើទម្រង់ជូនដំណឹងអំពីឧប្បត្តិហេតុ ការរំលោភបំពានផ្លូវភេទ ការរំលោភបំពាន និងការបៀតបៀន ដែលអាចរកបាននៅលើគេហទំព័ររបស់ DfAT ឬនៅលើកន្លែងរក្សារឯកសាររួមរបស់ SeeBeyondBorders ក្រោមនីតិវិធីដែលបានបោះពុម្ពផ្សាយហើយផ្ញើអ៊ីមែលទៅ seah.reports@dfat.gov.au

ករណីសង្ស័យ ឬចោទប្រកាន់ទាំងអស់ស្តីពី SEAH ទាក់ទងនឹងកម្មវិធីដែលផ្តល់មូលនិធិដោយ FCDO ត្រូវតែរាយការណ៍ទៅ Mannion Daniels អ្នកគ្រប់គ្រងមូលនិធិ FCDO នៅចក្រភពអង់គ្លេសតាមរយៈ

ukaidsafeguarding@manniondaniels.com

SeeBeyondBorders នឹងធ្វើការស៊ើបអង្កេតរាល់កង្វល់ទាំងអស់ ដែលបានរាយការណ៍មកយើងភ្លាមៗនិងផ្តល់ការឆ្លើយតបដូចបានរៀបរាប់ខាងក្រោម។

## 10. ការឆ្លើយតប

អង្គការទស្សនៈឥតព្រំដែននឹងតាមដានរបាយការណ៍កិច្ចការពារសុវត្ថិភាព និង SAEH និងការព្រួយបារម្ភយោងតាមគោលនយោបាយនិងនីតិវិធី និងកាតព្វកិច្ចដែលកំណត់ដោយច្បាប់ (សូមមើលពីនីតិវិធីគ្រប់គ្រងការការពារកុមារ និងជនងាយរងគ្រោះ នៅក្នុងគោលនយោបាយពាក់ព័ន្ធ) ។ នីតិវិធីទាំងនេះរួមបញ្ចូលទាំងកាតព្វកិច្ចរបស់យើង ក្នុងការរាយការណ៍អំពីឧប្បត្តិហេតុ ឬការរំលោភគោលនយោបាយចំពោះមុខម្ចាស់មូលនិធិខាងក្រៅដូចជា DfAT នៅអូស្ត្រាលី និងFCDO នៅចក្រភពអង់គ្លេស) ។

អង្គការទស្សនៈឥតព្រំដែននឹងអនុវត្តវិធានការវិន័យសមស្របដល់បុគ្គលិកដែលរកឃើញថារំលោភគោលនយោបាយ។

អង្គការទស្សនៈឥតព្រំដែននឹងផ្តល់ការគាំទ្រដល់អ្នករស់រានមានជីវិតពីគ្រោះថ្នាក់ដែលបណ្តាលមកពីបុគ្គលិក អ្នកស្ម័គ្រចិត្ត ឬភ្ញៀវដោយមិនប្រកាន់ថាមានការឆ្លើយតបផ្ទៃក្នុងជាផ្លូវការត្រូវបានធ្វើឡើង (ដូចជាការស៊ើបអង្កេតផ្ទៃក្នុង)ឬអត់នោះឡើយ ។ ការសម្រេចចិត្តទាក់ទងនឹងការគាំទ្រនឹងត្រូវដឹកនាំដោយអ្នករងគ្រោះ ឬអ្នករួចផុតពីគ្រោះថ្នាក់។

## 11. ការរក្សាការសំខាត់

វាជាការសំខាន់ក្នុងការរក្សាការសម្ងាត់នៅគ្រប់ដំណាក់កាលនៃដំណើរការនៅពេលដោះស្រាយជាមួយការព្រួយបារម្ភអំពីកិច្ចការពារសុវត្ថិភាព។ ពត៌មានទាក់ទងនឹងការព្រួយបារម្ភ និងការគ្រប់គ្រងករណីជាបន្ត

បន្ទាប់គួរតែត្រូវបានចែករំលែកតែក្នុងលក្ខខណ្ឌតម្រូវការចាំបាច់ដើម្បីដឹងអំពីមូលដ្ឋានតែប៉ុណ្ណោះ ហើយគួរតែត្រូវបានរក្សាសុវត្ថិភាពគ្រប់ពេល។

## 12. គោលនយោបាយនិងនីតិវិធីដែលពាក់ព័ន្ធ

- គោលនយោបាយប្រឆាំងនឹងការរើសអើង ធ្វើទុក្ខបុកម្នេញ និងការបៀតបៀន Anti-Discrimination, Bullying and Harassment policy
- គោលនយោបាយការពារអ្នកទទួលផលជាកុមារនិងជនងាយរងគ្រោះChild and Vulnerable Beneficiary Protection policy
- ក្រមសីលធម៌ Code of Conduct
- គោលនយោបាយស្ដីពីបណ្ដឹងតវ៉ា និងព័ត៌មានត្រឡប់ Complaints and Feedback Handling Policy
- សៀវភៅណែនាំធនធានមនុស្ស HR Manual
- គោលនយោបាយរូបភាព Images Policy
- និតិវិធីការគ្រប់គ្រងការការពារសុវត្ថិភាព កុមារនិងជនងាយរងគ្រោះ Child and Vulnerable People Protection and Safeguarding Management procedures
- នីតិវិធីសម្រាប់កិច្ចការពារសុវត្ថិភាពក្នុងការជ្រើសរើសបុគ្គលិក Procedures for safeguarding in staff recruitment
- គោលនយោបាយគ្រប់គ្រងហានិភ័យ Risk Management Policy
- តារាងវាយតម្លៃហានិភ័យ Risk Assessment Matrix
- គោលនយោបាយបន្លឺសំឡេង Whistleblowing policy
- គោលនយោបាយផ្សេងៗទៀតដែលសមស្រប

## 13. ការគ្រប់គ្រងគោលនយោបាយ

គោលការណ៍នេះ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាអូស្រ្តាលី និងអ្នកទទួលខុសត្រូវនៃអង្គភាពផ្សេងទៀតរបស់អង្គការទស្សនៈតព្រំដែនដូចដែលបានកត់សម្គាល់ខាងក្រោម។ ការធ្វើវិសោធនកម្ម និងការអភិវឌ្ឍ នឹងត្រូវផ្តល់អនុសាសន៍ ដល់ក្រុមប្រឹក្សាភិបាល ពីពេលមួយទៅពេលមួយតាមការចាត់តាំងសមស្រប របស់ថ្នាក់ដឹកនាំជាន់ខ្ពស់។ ការពិនិត្យឡើងវិញជាផ្លូវការ ត្រូវបានធ្វើឡើងក្នុងរយៈពេលបីឆ្នាំ គិតចាប់ពីថ្ងៃគម្រប់ខួបនៃការអនុម័តដោយក្រុមប្រឹក្សាភិបាល។ អនុសាសន៍សម្រាប់ការផ្លាស់ប្តូរតិចតួចអាចត្រូវបានអនុម័តដោយនាយកប្រតិបត្តិ មុនពេលក្រុមប្រឹក្សាត្រួតពិនិត្យរៀងរាល់បីឆ្នាំម្តង ហើយអនុសាសន៍សម្រាប់ការផ្លាស់ប្តូរផ្ទៃខាងក្រោយ ឬគោលនយោបាយ ក្នុងការអនុវត្តអាចត្រូវបានអនុម័តដោយអនុគណៈកម្មការពាក់ព័ន្ធ។

| Doc ref | Doc type | Approved by Australian Board Date | Minute ref. | Approved by UK Trustees Date | Minute ref | Approved by Irish Board Date | Minute ref |
|---|---|---|---|---|---|---|---|
| | Policy Original | Board<br>21 Aug 2018 | | 11 Oct 2018 | Minutes: 11/10/18 | N/A | N/A |
| SP/06/2020/1.0 | Policy Update | Board<br>29 June 2020 | Item 8 | 21 July 2020 | Agenda item 5 | | |
| SP/06/2020/1.1 | Policy Amendment | CEO Note<br>11 Nov 2020 | | CEO Note<br>11 Nov 2020 | | | |
| SP/02/2021/2.0 | Policy Review | | | | | | |

## ឧបសម្ព័ន្ធ ក៖ ជនបង្គោលការពារសុវត្ថិភាព (Safeguarding Focal Points)

| ប្រទេស | ឈ្មោះ | មុខតំណែង | ទូរស័ព្ទ |
|---|---|---|---|
| កម្ពុជា | ឡុក តាំងអ៊ីម | Child Protection Officer | +855 (0)63 5070 888 |
| អូស្ត្រាលី | Priscilla Chang | Board Member | +61 (0)2 9960 7077 |
| ចក្រភពអង់គ្លេស | Jayne Crow | Trustee | +44 (0)7834 536334 |
| អៀរឡង់ | Maeve Corish | Chair | +353 (0)86 375 6554 |

គ្រប់ជនបង្គោលការពារសុវត្ថិភាពសុទ្ធតែអាចទាក់ទងបានតាមរយៈ
email: safeguarding@seebeyondborders.org